## ៥- សមាទាន ឧបោសថសីល (សីល៨)

សីល៨ ពុទ្ធបរិស័ទជាគ្រហស្ថ ទទួលកាន់យកនៅថ្ងៃសីល (ថ្ងៃ៨កើត ៨រោច ១៥កើត ១៥រោច) ហៅថាថ្ងៃឧបោសថ ខុសប្លែកអំពីសីល៥ត្រង់សិក្ខាបទ៣ថែមទៀតលើសពីសីល៥ ដូចជា វៀរ ហូបបាយពេលល្ងាចឬសេព នូវមេថុនធម្ម។ ដោយបាលីខាងដើមដូចគ្នាខុសតែសីល៥ជំនួសជាពាក្យសីល៨ ខ្ញុំសូមលើកយកតែពាក្យប្រៀនប្រដៅទាំង៨ ដូចតទៅនេះ ៖

**-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ។** (ប្រែដូច និច្ចសីល) ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ។** (ប្រែដូច និច្ចសីល) ។

**-អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ។** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

**-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ។** (ប្រែដូច និច្ចសីល) ។

**-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។** (ប្រែដូច និច្ចសីល) ។

**-វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ។** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស ។

**-នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ

វៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសល

ធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង

និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេង ៗ។

**-ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ។**

ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈ ដ៏ខ្ពស់ ហួសប្រមាណ និងទីសេនាសនៈ ដ៏ប្រសើរ។

បន្ទាប់មក អ្នកសមាទាន សូត្រជាបាលី និង សម្រាយ ដូច តទៅនេះ ៖

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធបញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ**

**សម្មទេវអភិរក្ខិតុំ សមាទិយាមិ។**

ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ៨ ដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៌ប្រពៃ

អស់កាលកំណត់ថ្ងៃនេះនិងយប់នេះ សូមកុសលចូរជាឧបនិស្ស័យ ធ្វើឲ្យច្បាស់

នូវព្រះនិព្វាន ក្នុងដ៏អនាគតទៅឯមុខ នោះហោង ៕

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ " ← " ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។